unhs 5-2007:WAF.05.07 4/27/2010 11:37 PM Page 1

កុមារគ្រប់រូប មានការវិវឌ្ឍតាមដំណាក់កាលលូតលាស់រៀងៗខ្លួនរបស់ពួកគេ ។
ជារឿងសំខាន់ណាស់សំរាប់លោកអ្នក ក្នុងការតាមដានពិនិត្យមើលអំពីការនិយាយស្តី
និងភាសារបស់កូនលោកអ្នក ហើយត្រូវស្នើសុំជំនួយ បើសិនជាលោកអ្នកមានការព្រួយបារម្ភ ។

6 ទៅ 10 ខែ

- ងាកក្បាលទៅរកសំលេងណាមួយដែលគួរឱ្យចាប់អារម្មណ៍
- កំកែកករ ("ម៉ាម៉ា" "បាបា" "ដាដា")
- ចាប់ផ្តើមត្រាប់តាមសំលេងដែលគេនិយាយ
- យល់ពីពាក្យ "no," "bye-bye," និងពាក្យដទៃ ទៀតដែលគេប្រើជាទូទៅ

10 ទៅ 15 ខែ

- ចង្អុល ឬសំឡឹងមើលវត្ថុ ឬមនុស្ស នៅពេលដែលគេបង្គាប់ឱ្យធ្វើដូច្នោះ
- ត្រាប់តាមពាក្យ និងសំលេងងាយៗ
- លោត ឬធ្វើសំលេង នៅពេលចាក់ភ្លេង
- ចូលចិត្តលេងហ្គេម ដូចជា "ល្បែងបិទពួន" និង "ល្បែងបូត សណ្តែក"

15 ទៅ 18 ខែ

- ធ្វើតាមការបង្គាប់ងាយៗ ដូចជា "ឱ្យបាល់មកខ្ញុំ"
- ឆ្លើយនៅពេលគេហៅឈ្មោះពីបន្ទប់មួយផ្សេងទៀត
- មានសកម្មភាពនៅពេលឮចំរៀង ឬតន្ត្រី
- យល់ពីសំណួរសមញ្ញបែប yes-no
- ប្រើបាន 10-20ពាក្យ
- ត្រឹមអាយុ 18 ខែ គួរតែអាចប្រើពាក្យបានច្រើនជាងនេះ

18 ទៅ 24 ខែ

- ប្រើបាន 20 ពាក្យ ឬច្រើនជាងនេះ
- ប្រើពាក្យ 2 ចូលគ្នា "ទឹកផ្លែឈើ ថែមទៀត" ឬ "ចង់បាន នំឃុកឃី"
- ចូលចិត្តស្តាប់រឿង និងចំរៀងសមញ្ញ។

24 ទៅ 36 ខែ

- ប្រើបាន 30 ពាក្យ ឬច្រើនជាងនេះ
- ប្រើប្រយោគដែលមាន 2-3ពាក្យ
- អាចយំនាក់ចំនងបានច្រើនតាមតម្រូវការ

ការិយាល័យសេវាកម្មអន្តរាគមន៍ដល់កុមារ
កម្មវិធីសោតវិញ្ញាណសំរាប់ទារក
ទូរស័ព្ទ (614)-644-8389
1-800-755-GROW
www.ohiohelpmegrow.org

Cut here and save

ការកំណត់អត្តសញ្ញាណពីភ្លេង គឺជាការសំខាន់

កម្មវិធីពីរដែលអនុវត្តទូទាំងរដ្ឋ បំរើរសេវាជូនលោកអ្នក និងកូនៗរបស់លោកអ្នក ដោយឥតគិតថ្លៃ។ កម្មវិធីទាំងពីរ គឺសំរាប់ទារក និងកុមារ ដែលមានអាយុរហូតដល់ទៅ 3 ឆ្នាំ:

1 ភម្មវិធីជួយឱ្យខ្ញុំលូតលាស់- Help Me Grow (HMG) 1-800-755-GROW

2 ភម្មវិធីសោតវិញ្ញាណសំរាប់ទារកប្រចាំតំបន់ - Regional Infant Hearing Program (RIHP)

កម្មវិធី RIHP អាចផ្តល់ជូនលោកអ្នកនូវសេវាកម្ម តាមផ្ទះដែលអាចជួយ លោកអ្នកបាន ក្នុងការប្រាស្រ័យទាក់ទងជាមួយទារក។ មានវិធីច្រើនយ៉ាងដែលទារកអាចប្រាស្រ័យទាក់ទងជាមួយលោកអ្នក។ ជម្រើសខ្លះ រួមមានការប្រើភាសា សញ្ញា ជំនួយខាងសោតវិញ្ញាណ ឧបករណ៍ ស៊ីកចូល ក្នុងរន្ធត្រចៀក ឬជាការបូកបញ្ចូលគ្នា នៃជម្រើសទាំងនេះ និងជម្រើសដទៃទៀត។ **សូមបន្តលេង និយាយ និងច្រៀងឱ្យកូនរបស់លោកអ្នកស្តាប់ ។**

សូមទំនាក់ទំនងមក ODH បើសិនជាលោកអ្នកមានសំណួរណាមួយ និងចូលមកមើលវែបសាយរបស់យើង (ដូចខាងក្រោម) ។ យើងអាចជួយរកសេវា កម្មក្នុងតំបន់របស់លោកអ្នកបាន ។



U.S. Department of Health and Human Services HRSA Health Resources and Services Administration Maternal and Child Health Bureau

OHIO DEPARTMENT OF HEALTH ODH

Ohio Family and Children First Initiative Help me grow

ការិយាល័យសេវាកម្មអន្តរាគមន៍ដល់កុមារ
កម្មវិធីសោតវិញ្ញាណសំរាប់ទារក
246 N. High Street,
Columbus, OH 43215
Phone (614)-644-8389
1-800-755-GROW
Fax (614) 728-9163
email:beis@odh.ohio.gov
www.ohiohelpmegrow.org

និយោជក/ក្រុមហ៊ុនដែលផ្តល់ឱកាសស្មើភាពគ្នា

សំលេងចាប់ផ្តើមឡើង...

ព័ត៌មានសំរាប់ឪពុកម្តាយ

ការធ្វើតេស្តសោតវិញ្ញាណដល់ទារកដែលទើបកើតទូទៅ (UNHS)

ច្បាប់រដ្ឋតម្រូវឱ្យកុមារ**ទាំងអស់** ធ្វើតេស្តសោតវិញ្ញាណមុនពេលចេញទៅសំរាកនៅផ្ទះ។ ការធ្វើតេស្តសោតវិញ្ញាណមានលក្ខណៈងាយស្រួល បើយមានសុវត្ថិភាព ។

ក្រសួងសុខាភិបាលរដ្ឋអូហៃយ៉ូ

unhs 5-2007:WAF.05.07 4/27/2010 11:37 PM Page 2

ការធ្វើតេស្តសោតវិញ្ញាណចល់ទារកដែលទើបកើត

តេស្តសោតវិញ្ញាណ គឺជាវិធីដ៏សមញ្ញមួយ ដើម្បីឱ្យដឹងថាកូនរបស់លោកអ្នកអាចស្តាប់ឮ ឬបើសិនជាគេត្រូវការធ្វើតេស្តថែមទៀត។ ទារកប្រើនូវសោតវិញ្ញាណរបស់ពួកគេ ដើម្បីអភិវឌ្ឍជំនាញផ្នែកនិយាយ និងភាសារបស់ពួកគេ ដែលជាជំនាញដ៏សំខាន់សំរាប់ការប្រាស្រ័យទាក់ទង។

1 តើគេធ្វើតេស្តសោតវិញ្ញាណដោយរបៀបណា?

- ★ កូនរបស់លោកអ្នកអាចគេងបានពេលកំពុងធ្វើតេស្ត។
- ★ ការធ្វើតេស្ត ត្រូវធ្វើក្នុងទារកដ្ឋាន ឬក្នុងបន្ទប់ស្ងាត់។
- ★ ការធ្វើតេស្ត ធ្វើឡើងយ៉ាងឆាប់រហ័ស (15 នាទី ឬតិចជាងនេះ)។

កូនរបស់លោកអ្នក អាចធ្វើតេស្តសោតវិញ្ញាណមួយ ឬទាំងពីរដូចខាងក្រោម:

ABR: (Auditory Brainstem Response)
បំណះបីបន្ទះ នឹងត្រូវគេដាក់លើមុខ ស្មា និងក របស់ទារក។ កាសត្រចៀកតូច នឹងត្រូវបានគេដាក់លើត្រចៀករបស់ទារក ហើយទារកអាចស្តាប់ឮសំលេងល្បឿងៗ។

OAE: (Otoacoustic Emissions)
ចុងកៅស៊ូសំឡី នឹងត្រូវគេដាក់ចូលក្នុងត្រចៀករបស់ទារក ហើយទារកអាចស្តាប់ឮសំលេងល្បឿងៗ។

ថានិច្ចកាល ត្រូវតាមដានពិនិត្យមើលពីដំណើរវិវឌ្ឍខាងការនិយាយស្តី និង ភាសា។

2 លទ្ធផលនៃការធ្វើតេស្តសោតវិញ្ញាណ:

លទ្ធផលជាប់ មានន័យថា:

➜ កូន បានធ្វើតេស្តសោតវិញ្ញាណជាប់ថ្ងៃនេះ។
★ ជានិច្ចកាល ត្រូវតាមដានពិនិត្យមើលពីដំណើរវិវឌ្ឍខាងការនិយាយស្តី និង ភាសា។

លទ្ធផលជាប់ ដោយមានកត្តាគ្រោះថ្នាក់ មានន័យថា:

➜ កូន បានធ្វើតេស្តសោតវិញ្ញាណជាប់ថ្ងៃនេះ។
★ កូនរបស់លោកអ្នកមានកត្តាគ្រោះថ្នាក់មួយ ឬច្រើន។ សូមពិគ្រោះយោបល់ជាមួយគ្រូពេទ្យរបស់កូនលោកអ្នក។
★ គេអាចត្រូវការធ្វើតេស្តថែមទៀត។ ជួនកាល ការបាត់បង់សោតវិញ្ញាណ អាចកើតឡើងនៅពេលក្រោយណាមួយ ក្នុងជីវិតរបស់ពួកគេ។

លទ្ធផលធ្លាក់ មានន័យថា: សូមមើលផ្នែកការធ្វើតេស្តតាមដានបន្ត

➜ កូន មិនបានធ្វើតេស្តជាប់ទេថ្ងៃនេះ។ ការធ្វើតេស្តបន្ថែមទៀត គឺជាការចាំបាច់សំរាប់កូនរបស់លោកអ្នក។
★ សោតវិញ្ញាណកូនរបស់លោកអ្នក ត្រូវឱ្យអ្នកជំនាញខាងសោតវិញ្ញាណ (គ្រូពេទ្យជំនាញខាងសោតវិញ្ញាណ) ពិនិត្យមើលម្តងទៀត។
★ ទឹកក្នុងត្រចៀក ឬមូលហេតុដទៃទៀត ក៏អាចបណ្តាលឱ្យមានលទ្ធផលនេះដែរ។
★ នេះមិនមានន័យថា កូនរបស់លោកអ្នក បាត់បង់សោតវិញ្ញាណនោះទេ ប៉ុន្តែការធ្វើតេស្តលម្អិតបន្ថែម គឺជាការចាំបាច់។
★ សូមរៀបចំពេលវេលាសំរាប់ធ្វើតេស្តតាមដានបន្ត ក្នុងរយៈពេលពីពីរទៅបីសប្តាហ៍ក្រោយពីលោកអ្នកចេញពីមន្ទីរពេទ្យទៅផ្ទះ។
★ មន្ទីរពេទ្យ នឹងផ្តល់ឱ្យលោកអ្នកនូវបញ្ជីអ្នកជំនាញខាងសោតវិញ្ញាណ ដែលអាចធ្វើតេស្តថែមទៀតលើកូនរបស់លោកអ្នក។
★ សូមកុំមានការភ្ញាក់ផ្អើល ឬភ័យខ្លាចចំពោះលទ្ធផលនេះ។

3 បើសិនជាកូនរបស់លោកអ្នក ត្រូវការតេស្តតាមដានបន្ត:

(ដោយសារលទ្ធផលមិនជាប់ ឬកត្តាគ្រោះថ្នាក់)

ជំហានបន្ទាប់:

(គោលដៅ: ការធ្វើតេស្ត ត្រូវបញ្ចប់ត្រឹមអាយុ 3-6 ខែ ឬមុននេះ)

1. សូមពិភាក្សាជាមួយគ្រូពេទ្យកូនរបស់លោកអ្នក អំពីលទ្ធផលនៅពេលពិនិត្យលើកដំបូង។
2. សូមរៀបចំពេលវេលាសំរាប់ធ្វើតេស្តតាមដានបន្ត ជាមួយអ្នកជំនាញខាងសោតវិញ្ញាណ (គ្រូពេទ្យជំនាញខាងសោតវិញ្ញាណ) ក្នុងរយៈពេលពីពីរទៅបីសប្តាហ៍នៃថ្ងៃកំណើតកូនរបស់លោកអ្នក។ សូមប្រើបញ្ជី ដែលផ្តល់ជូនដោយមន្ទីរពេទ្យ ដើម្បីស្វែងរកអ្នកជំនាញខាងសោតវិញ្ញាណ។
3. កម្មវិធីសោតវិញ្ញាណសំរាប់ទារកប្រចាំតំបន់ អាចជួយលោកអ្នកស្វែងរកអ្នកជំនាញខាងសោតវិញ្ញាណ ឬឆ្លើយនឹងសំណួរអំពីការធ្វើតេស្តតាមដានបន្ត។

4 ក្រោយពេលធ្វើតេស្តតាមដានបន្តកូនរបស់ខ្ញុំ មានបញ្ហាបាត់បង់សោតវិញ្ញាណ តើអ្វីជាជំហានបន្ទាប់?

(គោលដៅត្រឹមអាយុ 6 ខែ ឬមុននេះ)

1. គ្រូពេទ្យ ឬអ្នកជំនាញខាងសោតវិញ្ញាណ នឹងពិភាក្សាជាមួយលោកអ្នក អំពីការបាត់បង់សោតវិញ្ញាណរបស់កូនលោកអ្នក។
2. កម្មវិធីសោតវិញ្ញាណសំរាប់ទារកប្រចាំតំបន់ (RIHP) ក្នុងតំបន់របស់លោកអ្នក នឹងទាក់ទងទៅលោកអ្នក។
3. RIHP មានអ្នកប្រឹក្សាយោបល់ដែលមានបទពិសោធន៍ខ្ពស់ អាចឆ្លើយទៅនឹងសំណួររបស់លោកអ្នក ផ្តល់ព័ត៌មានជូនលោកអ្នកអំពី *ការបាត់បង់សោតវិញ្ញាណ អំពីជម្រើសនានាក្នុងការប្រាស្រ័យទាក់ទង* និងផ្តល់ការឧបត្ថម្ភដល់គ្រួសារ និងធនធានជាច្រើនទៀត។
4. កម្មវិធី Help Me Grow-Birth to Three (ការអន្តរាគមន៍ដល់កុមារ) នឹងផ្តល់ជូនឱ្យអ្នកសម្របសម្រួលសេវាកម្មម្នាក់សំរាប់គ្រួសាររបស់លោកអ្នក។
5. សូមបន្តទៅជួបអ្នកជំនាញខាងសោតវិញ្ញាណរបស់លោកអ្នក។
6. សូមទូរស័ព្ទទៅ ODH ដើម្បីជ្រាបព័ត៌មានបន្ថែមតាមលេខ 614-644-8389 ឬចូលទៅមើលវែបសាយ http://www.ohiohelpmegrow.org

គេអាចធ្វើតេស្តសោតវិញ្ញាណបាននៅគ្រប់វ័យទាំងអស់!

ការរៀនសូត្រចាប់ផ្តើមតាំងពីកំណើតមកម្ល៉េះ

★ សូម **រីករាយ** ជាមួយកូនរបស់លោកអ្នក ខណៈដែលពួកគេកំពុងលូតលាស់។ សូមនិយាយ ច្រៀង និងលេងជាមួយកូនរបស់លោកអ្នក។

ចំណាត់កាលចេះនិយាយ និង ប្រើភាសា

★ ទារកភាគច្រើន ដែលធ្វើតេស្តសោតវិញ្ញាណជាប់ពីកំណើត អាចរៀនភាសា និងនិយាយបាន។

★ ទារកខ្លះ ដែលធ្វើតេស្តសោតវិញ្ញាណជាប់នៅមន្ទីរពេទ្យ អាចមានការបាត់បង់សោតវិញ្ញាណវិញ នៅពេលក្រោយណាមួយក្នុងជីវិតរបស់ពួកគេ។

★ ជាការសំខាន់ណាស់សំរាប់លោកអ្នក ក្នុងការពិនិត្យតាមដានការវិវឌ្ឍខាងសោតវិញ្ញាណ ការនិយាយស្តី និងភាសារបស់កូនលោកអ្នក។

★ ជាការសំខាន់ណាស់ ដែលត្រូវយកកូនរបស់លោកអ្នកទៅឱ្យអ្នកជំនាញខាងសោតវិញ្ញាណ (គ្រូពេទ្យខាងសោតវិញ្ញាណ) ពិនិត្យ បើសិនជាលោកអ្នកមានកង្វល់អំពីសោតវិញ្ញាណរបស់កូន។

សូមប្រើតារាងដំណាក់កាល ជាជំនួយដល់លោកអ្នកក្នុងការពិនិត្យការវិវឌ្ឍខាងសោតវិញ្ញាណ ការនិយាយស្តី និងភាសារបស់កូន លោកអ្នក។

ពីកំណើតរហូតដល់ 3 ខែ

★ ភ្ញាក់ដោយបញ្ចេញសំលេងខ្លាំងៗ

★ នៅស្ងប់ស្ងៀម នៅពេលឮសំលេងដែលគេធ្លាប់ឮ

3 ទៅ 6 ខែ

★ ងាកក្បាលស្វែងរកសំលេង

★ ប្រើភ្នែកដើម្បីស្វែងរកសំលេង

★ អាចបន្លឺសូរញ៉ែកៗ ថ្ងូរហ៊ឺះៗ ឬបញ្ចេញសំលេងឮវិ។

★ ត្រាប់តាមសំលេងខ្លួនឯង - "អូប៉ី" "ប៉ា-ប៉ា"

★ សប្បាយជាមួយនឹងប្រដាប់អង្រួនលេង និងរបស់លេងដទៃទៀតដែលអាចធ្វើឱ្យឮសំលេង។

មានតទៅម្ខាងទៀត

ការបាត់បង់សោតវិញ្ញាណ ឬតិចតួច អាចបណ្តាលឱ្យមានការយឺតយ៉ាវខាងការនិយាយស្តី ភាសា និងការប្រាស្រ័យទាក់ទងរបស់កូនលោកអ្នក។